01421225

E449/3/4

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 03 / 2017
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

**ផ្ញើជូន៖** ឯ.ឧ ក្រាញ់ តូនី — ថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០១៧

ប្រធានស្តីទីនៃការិយាល័យរដ្ឋបាល

លោក **Knut ROSANDHAUG**

អនុប្រធានការិយាល័យរដ្ឋបាល

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

ភាគីទាំងអស់នៃសំណុំរឿង ០០២/០២

**កម្មវត្ថុ៖** **ការសាកសួរបន្ថែមទៀត ពាក់ព័ន្ធនឹងការរៀបចំបញ្ចប់ប្រតិចារឹក**

១. អង្គជំនុំជម្រះសាលាដំបូងទទួលបានចម្លើយតបរបស់ឯកឧត្តមប្រធាន និងលោកអនុប្រធាន ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ ទៅនឹងការសាកសួររបស់អង្គជំនុំជម្រះ ពាក់ព័ន្ធនឹងការរៀបចំបញ្ចប់ប្រតិចារឹកសំណុំរឿង ០០២/០២ (ឯកសារ E449/3/3) ដែលក្នុងចម្លើយតបនោះ ឯកឧត្តមប្រធាន និងលោកអនុប្រធាន បានព្យាករកាលបរិច្ឆេទនៃការបញ្ចប់ប្រតិចារឹក។ ព័ត៌មានចុងក្រោយដែលទទួលបានពីការិយាល័យរដ្ឋបាលបានបង្ហាញថា ប្រតិចារឹកទាំងអស់នឹងត្រូវបញ្ចប់ "នៅត្រឹមដំណាច់ខែ មិថុនា ឆ្នាំ ២០១៧ ឬមុនកាលបរិច្ឆេទនេះ" ហើយការ

ព្យាករណ៍កាលបរិច្ឆេទថ្មីសម្រាប់ប្រតិចារឹកភាសាបារាំង និងភាសាខ្មែរចុងក្រោយ គឺនៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៧ (ឯកសារ E449/2/1 កថាខណ្ឌ ២, ឯកសារ E449/3/3 កថាខណ្ឌ ២(ង))។

២. មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះណែនាំការិយាល័យរដ្ឋបាលកំណត់យកថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៧ ជាកាលបរិច្ឆេទដាក់ប្រតិចារឹកស្តាពរសំណុំរឿង ០០២/០២ ទាំងអស់ ដោយយល់ឃើញថា ប្រតិចារឹកទាំងនេះមានសារៈសំខាន់ចំពោះការសរសេរសេចក្តីព្រាងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន (ឯកសារ E449/3 កថាខណ្ឌ ២៣, ២៥)។ មេធាវីការពារក្តី នួន ជា បញ្ជាក់ថា "មេធាវីការពារក្តីអាចត្រូវបង្ខំចិត្តស្នើការពន្យាពេលដើម្បីធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលផ្ទាល់មាត់ អាស្រ័យលើថា តើពេលណាប្រតិចារឹកដែលបានត្រួតពិនិត្យឡើងវិញត្រូវបានធ្វើរួចរាល់ ដើម្បីរៀបចំការពារ នួន ជា ឱ្យបានត្រឹមត្រូវ" (ឯកសារ E449/3 កថាខណ្ឌ ២៤)។

៣. ដោយពិចារណាលើចំណុចនេះ អង្គជំនុំជម្រះស្នើសុំឱ្យការិយាល័យរដ្ឋបាលជូនដំណឹងមកអង្គជំនុំជម្រះ (១) ថាតើ ដំណើរការពិនិត្យមើលប្រតិចារឹកឡើងវិញនេះ អាចបញ្ចប់នៅមុនកាលបរិច្ឆេទដែលបានព្យាករពីមុននៅក្នុងចម្លើយតបរបស់ឯកឧត្តម និងលោក ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧ ដោយមិនកាត់បន្ថយគុណភាពប្រតិចារឹកបានដែរ ឬទេ និង (២) ប្រសិនបើអាចបញ្ចប់នៅមុនកាលបរិច្ឆេទដែលបានព្យាករនោះ តើអាចបញ្ចប់នៅពេលណា។ អង្គជំនុំជម្រះស្នើសុំឱ្យឯកឧត្តមប្រធាន និងលោកអនុប្រធាន ផ្តល់ចម្លើយនៅត្រឹមថ្ងៃ ច័ន្ទ ទី ២៧ ខែ មីនា ឆ្នាំ ២០១៧។